ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣៣៣

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ២១៧ សជណ ធទឧ

# សេចក្តីជូនដំណឹង

ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា បន្ទាប់ពីបានធ្វើការសង្កេត តាមដានលើស្ថានភាពអាកាសធាតុរួចមក ឃើញថា : នៅវេលាម៉ោង 01 រំលងអធ្រាត ឈានចូលថ្ងៃទី 21 ខែកញ្ញា ឆ្នាំ 2011 មានប្រព័ន្ធសម្ពាធទាប និងជ្រលងសម្ពាធទាបបានរំកិលមកលើភាគខាងជើងប្រទេសកម្ពុជា ។ ឥទ្ធិពលនៃបាតុភូតធម្មជាតិទាំងពីរខាងលើនេះ នឹងធ្វើឱ្យព្រះរាជាណាចក្រកម្ពុជាមានភ្លៀងធ្លាក់រាយប៉ាយច្រើនទូទាំងប្រទេសជាបន្តបន្ទាប់ចាប់ពីថ្ងៃទី 23 ដល់ថ្ងៃទី 26 ខែកញ្ញា ឆ្នាំ 2011 និងអាចបង្កឱ្យមានជំនន់ទឹកភ្លៀង នៅតំបន់វាលទំនាបដែលមានភូមិសាស្ត្រជាប់នឹងតំបន់ភ្នំ តំបន់ជូរភ្នំ តំបន់ខ្ពង់រាប និងតំបន់មាត់សមុទ្រ រួមមានខេត្ត : ព្រះវិហារ រតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ក្រចេះ កំពង់ចាម ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ កណ្តាល តាកែវ កំពង់ស្ពឺ កំពត កែប កោះកុង និងខេត្តព្រះសីហនុ ។ ផ្ទៃសមុទ្រកម្ពុជានឹងមានរលកបោកបក់ខ្លាំង និងអាចមានកំពស់ពី 1,50 ទៅ 2 ម៉ែត្រ ។

យោងតាមស្ថានភាពធាតុអាកាសខាងលើ ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់អាជ្ញាធរដែនដី និងប្រជាពលរដ្ឋដែលរស់នៅតាមបណ្តាខេត្តដូចបានជម្រាបជូនខាងលើ ពិសេស បងប្អូនដែលរស់នៅជាប់នឹងផ្លូវទឹក អ្នកធ្វើដំណើរតាមផ្លូវទឹក ប្រជានេសាទ សូម **បង្កើនការយកចិត្តទុកដាក់ប្រុងប្រយ័ត្នខ្ពស់** ដើម្បីចៀសវាងនូវគ្រោះថ្នាក់ផ្សេងៗ ដែលអាចកើតមានឡើងជាយថាហេតុ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ ២០១១

រដ្ឋមន្ត្រី

លឹម គានហោ